# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីនីតិវិធីនៃការបើកផ្តល់មុនបណ្តោះអាសន្ន ដោយអាណត្តិបើកប្រាក់ សំរាប់ចំណាយរៀបចំប្រជុំកំពូលអាស៊ានឆ្នាំ២០០២ និងចំណាយរៀបចំប្រជុំកំពូល នៃប្រទេសស្ថិតក្នុងមហាអនុតំបន់ទន្លេមេគង្គ ឆ្នាំ២០០២

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបាន កែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** -អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនីតិវិធីបើកផ្តល់មុនបណ្តោះអាសន្នដោយអាណត្តិបើកប្រាក់សំរាប់ ដោយឡែកតែទៅលើ :

- ចំណាយសំរាប់រៀបចំការប្រជុំកំពូលអាស៊ានឆ្នាំ២០០២ នៅភ្នំពេញ
- ចំណាយសំរាប់រៀបចំការប្រជុំកំពូលនៃប្រទេសស្ថិតក្នុងមហាអនុតំបន់មេគង្គឆ្នាំ២០០២។

គោលដៅនៃកិច្ចប្រតិបត្តិការនេះ គឺ ដើម្បីអោយកិច្ចប្រតិបត្តិការចំណាយថវិកាឆ្លុះបញ្ចាំងទៅក្នុងតារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋនិងធានាសម្រេចអោយបានទាន់ពេលវេលាដល់កិច្ចការទាំងពីរខាងលើ ។

**មាត្រា២:** -ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា ៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងមាត្រា ៩ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល រាល់ការបើកផ្តល់មុនបណ្តោះអាសន្នសំរាប់មុខសញ្ញាចំណាយទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៣ ខាងក្រោម ត្រូវធ្វើឡើងដោយអាណត្តិបើកប្រាក់ដោយគ្រាន់តែភ្ជាប់មកជាមួយនូវគំរោងចំណាយលំអិត ។

**មាត្រា៣:** -មុខសញ្ញាចំណាយដែលបើកផ្តល់មុនបណ្តោះអាសន្នដោយអាណត្តិបើកប្រាក់មានដូចតទៅ :

- ចំណាយសំរាប់រៀបចំការប្រជុំកំពូលអាស៊ានឆ្នាំ២០០២ នៅភ្នំពេញ
- ចំណាយសំរាប់រៀបចំការប្រជុំកំពូលនៃប្រទេសស្ថិតក្នុងមហាអនុតំបន់មេគង្គឆ្នាំ២០០២។

**មាត្រា៤:** -ក្រសួង ស្ថាប័នដែលគ្រប់គ្រងចំណាយដូចបានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវមានភារកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុយ៉ាងយូរបំផុតមួយសប្តាហ៍ក្រោយថ្ងៃបញ្ចប់ ។ ក្នុងករណីមានប្រាក់នៅសល់ត្រូវបង់ចូលថវិការដ្ឋវិញ ។

**មាត្រា៥:** មុខសញ្ញាចំណាយទាំងពីរនេះត្រូវស្ថិតក្រោមយន្តការនៃការធ្វើសវនកម្មក្រោយចំណាយ ។

ឞ

**មាត្រា៦:** -កិច្ចប្រតិបត្តិការចំណាយទាំងអស់នេះ ត្រូវមានការណែនាំអនុវត្តដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៧:** -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧ ដើម្បីអនុវត្ត
-ឯកសារ-កាលប្បវត្តិ